ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៣៣ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកាត់ផ្ទៃដីទំហំ ៤៤០ ហិកតា ចេញពីដែនគម្របព្រៃឈើឆ្នាំ២០០២ និងធ្វើអនុបយោគពីដីសាធារណៈរបស់រដ្ឋមកជាដីឯកជនរបស់រដ្ឋ សម្រាប់អនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចជូនប្រជាពលរដ្ឋក្រីក្រគ្មានដីពិតប្រាកដ ស្ថិតនៅក្នុងឃុំប៉ោយចារ ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២០/០៣០ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងនីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា១.-**

កាត់ផ្ទៃដីទំហំ ៤៤០ ហិកតា ចេញពីដែនគម្របព្រៃឈើឆ្នាំ២០០២ និងធ្វើអនុបយោគពីដីសាធារណៈរបស់រដ្ឋមកជាដីឯកជនរបស់រដ្ឋ សម្រាប់អនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចជូនប្រជាពលរដ្ឋក្រីក្រគ្មានដីពិតប្រាកដ ក្រោមគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ដំណាក់កាលទី៣ (LASED III) ស្ថិតនៅក្នុងឃុំប៉ោយចារ ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 ដូចមានផែនទីបង្ហាញទីតាំងដី និងតារាងនិយាមកាក្នុងឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ។

**មាត្រា២.-**

ប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ខាងលើ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបន្ទាយមានជ័យ ដើម្បីធ្វើការគ្រប់គ្រង និងចាត់ចែងស្របតាមនីតិវិធីជាធរមាន។

**មាត្រា៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ១២ កើត ខែ ចេត្រ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មេសា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ផែនទី និងតារាងនិយាមការឧបសម្ព័ន្ធអនុក្រឹត្យលេខ............៣៧...អនក្រ.បក.................ចុះថ្ងៃទី...១៣...ខែ..មេសា..ឆ្នាំ២០២២




| តារាងនិយាមការចំណុចព្រំដី | | |
|---|---|---|
| Projection UTM,Zone48N,DatumWGS84 | | |
| Point | Northing(m) | Easting(m) |
| 1 | 1542016.7983 | 307304.2184 |
| 2 | 1542581.9539 | 309474.8436 |
| 3 | 1540804.5496 | 308953.8318 |
| 4 | 1540836.8986 | 308843.4750 |
| 5 | 1539140.0281 | 308348.1675 |
| 6 | 1539140.9874 | 307660.3602 |

**សញ្ញាសម្គាល់**

● ចំណុចព្រំដីស្នើសុំកាត់ចេញពីដែនគម្របព្រៃឈើឆ្នាំ២០០២

▨ ដីទំហំ ៤៤០ហិកតា ស្នើសុំកាត់ចេញពីដែនគម្របព្រៃឈើ ឆ្នាំ២០០២

ផែនទីបង្ហាញទីតាំងដីទំហំ ៤៤០ហិកតា ដែលស្នើសុំកាត់ចេញពីដែនគម្របព្រៃឈើឆ្នាំ២០០២
និងធ្វើអនុបយោគពីដីសាធារណៈរបស់រដ្ឋមកជាដីឯកជនរបស់រដ្ឋ សម្រាប់កម្មវិធីសម្បទានដីសង្គមកិច្ច ជូនប្រជាពលរដ្ឋក្រីក្រដែលគ្មានដីពិតប្រាកដ
ស្ថិតនៅឃុំប៉ោយចារ ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ




តារាងនិយាមកាចំណុចព្រំដី

Projection UTM,Zone48N,DatumWGS84

| Point | Northing(m) | Easting(m) |
|---|---|---|
| 1 | 1542016.7983 | 307304.2184 |
| 2 | 1542581.9539 | 309474.8436 |
| 3 | 1540804.5496 | 308953.8318 |
| 4 | 1540836.8986 | 308843.4750 |
| 5 | 1539140.0281 | 308348.1675 |
| 6 | 1539140.9874 | 307660.3602 |

សញ្ញាសម្គាល់

● ចំណុចព្រំដីស្នើសុំកាត់ចេញពីដែនគម្របព្រៃឈើឆ្នាំ២០០២

▨ ដីទំហំ ៤៤០ហិកតា ស្នើសុំកាត់ចេញពីដែនគម្របព្រៃឈើឆ្នាំ២០០២